ចាប់បើកអាជីវកម្ម
នៅទ្បុងប៊ិច



ទ្បុងប៊ិចជាទីក្រុងដែលស្រួលបើកអាជីវកម្មជាងគេមួយដែរ ក្នុងតំបន LOS ANGELES

LONGBEACH
ECONOMIC
DEVELOPMENT
& OPPORTUNITY

ចាប់ផ្តើមបើករបរអាជីវកម្មរបស់អ្នក នៅក្នុងទីក្រុងឡុងប៊ិច

ទីក្រុងឡុងប៊ិច ជាទីដែលរបរអាជីវកម្មជោគជ័យ។ សាលាក្រុងមានក្រុមគាំពារចាំជួយ និងមានឧស្សាហកម្ម និងធនធានសំខាន់ៗ ដែលយើងជួយឲ្យអាជីវកម្ម ងាយស្រួលបើកដំណើរការ រីកចម្រើន និងជោគជ័យ។ នាយកដ្ឋានសេដ្ឋកិច្ច អភិវឌ្ឍន៍ និងឱកាស ត្រៀមខ្លួនជានិច្ចដើម្បីជួយអ្នក មិនថាជួយដាក់ពាក្យសុំលិខិតអនុញ្ញាត ជួយរកជំនួយថវិកា ឬណែនាំឲ្យទទួលបានឱកាសថ្មីៗនោះឡើយ។

បញ្ជីផ្លូវដ្ឋាត់នេះ គឺជាផែនទីបង្ហាញផ្លូវមួយ ឆ្ពោះទៅកាន់ភាពជោគជ័យ ក្នុងការបើកអាជីវកម្ម នៅឡុងប៊ិច។ សូមអនុវត្តតាមដំណាក់កាលនីមួយៗ និងប្រើប្រាស់ធនធានដែលសាលាក្រុងផ្តល់ជូន នោះអ្នកនឹងអាចកសាងមូលដ្ឋានគ្រឹះរឹងមាំ ដើម្បីបើកអាជីវកម្ម និងធ្វើឲ្យមុខរបរនេះ ទទួលបានជោគជ័យ ដោយភាពជឿជាក់។

ទីក្រុងឡុងប៊ិចសូមស្វាគមន៍! ទីនេះហើយ ដែលអាជីវកម្មរបស់អ្នកមានអនាគត! យើងខ្ញុំត្រៀមខ្លួនជានិច្ច ដើម្បីជួយអ្នកនៅគ្រប់ដំណាក់កាល!

សូមស្កែន ដើម្បីបានដឹងព័ត៌មាន និងពិនិត្យមើលឯកសារនេះជាភាសាផ្សេងពីនេះ។

ចាប់ផ្តើមបើករបរអាជីវកម្ម

ជំហានទី ១៖ រៀបចំផែនការរបរអាជីវកម្មរបស់អ្នក

- ☐ គិតរករបរអាជីវកម្មអ្វី និងមានគោលដៅអ្វីខ្លះ។
- ☐ រៀបចំផែនការមុខរបរនោះ ដោយប្រើគ្រោងផែនការដែលមានស្រាប់៖
  - ការគ្រប់គ្រងអាជីវកម្មខ្នាតតូច៖ sba.gov
  - SCORE: score.org
- ☐ ជ្រើសរើសរចនាសម្ព័ន្ធអាជីវកម្មរបស់អ្នក
  (ឯកត្តបុគ្គល ទទួលខុសត្រូវមានកម្រិត សាជីវកម្ម ។ល។)
- ☐ ប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់បើកដំបូង និងថវិកាប្រតិបត្តិ។
- ☐ រើសទីប្រឹក្សា (អ្នកពិគ្រោះយោបល់ មេធាវី គណនេយ្យករ ។ល។)

ជំហានទី ២៖ រកហិរញ្ញវត្ថុសម្រាប់អាជីវកម្មរបស់អ្នក

- ☐ គណនាថ្លៃដើមទុន ដែលអ្នកត្រូវការ ដើម្បីបើករបរនេះ និងដើម្បីឲ្យរបរនេះនៅដំណើរការ។
- ☐ រៀបចំការព្យាករណ៍ហិរញ្ញវត្ថុ សម្រាប់រយៈពេលយ៉ាងតិចបីឆ្នាំ។
- ☐ ឆែកមើលពិន្ទុក្រេឌីតរបស់អ្នក។
- ☐ រកមើលប្រភពជំនួយថវិកា៖
  - កម្មវិធីឥណទានសហគ្រាសធុនតូច
  - ថវិកាគម្រោងលូតលាស់ទ្បង់ប៊ិច
- ☐ បើកគណនីធនាគារសម្រាប់អាជីវកម្ម។

ជំហានទី ៣៖ រើសទីតាំង

- ☐ រកមើលកន្លែងសម្រាប់បើករបរអាជីវកម្មនោះ (នៅផ្ទះ ចល័ត ឬហាង)។
- ☐ ស្រាវជ្រាវបទប្បញ្ញត្តិអំពីការកំណត់តំបន់លក់ដូរបាន៖
  - មើលផែនទីបង្ហាញតំបន់លក់ដូរបាន តាមនេះ៖ longbeach.gov/zoningmap
  - ផ្ទៀងផ្ទាត់ការអនុវត្តាមការកំណត់តំបន់លក់ដូរបាននោះសិន មុននឹងចុះកិច្ចសន្យាជួលកន្លែង។
- ☐ វាយតម្លៃទីតាំងនោះ រកមើលច្រកងាយចេញចូល ថ្មើរជើង និងហេដ្ឋារចនាសម្ព័ន្ធ។
  - វិធានសម្រាប់ឈ្វេងយល់បន្ថែមអំពីអាជីវកម្ម៖ longbeach.sizeup.com
- ☐ ផ្ទៀងផ្ទាត់ការអនុវត្តច្បាប់ស្តីពីជនពិការ។
- ☐ ទាក់ទងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ដើម្បីបញ្ជាក់អំពីការកំណត់តំបន់ដែលអាចលក់ដូរបាននោះ។
- ☐ ចរចាលក្ខខណ្ឌជួលកន្លែងលក់ដូរ។

Tepechi Restaurant

Uptown Commons

ចុះបញ្ជីអាជីវកម្ម អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត

ជំហានទី ៤៖ ចុះបញ្ជីអាជីវកម្មរបស់អ្នក

- ☐ **ចុះឈ្មោះអាជីវកម្មរបស់អ្នក**
  ដាក់ពាក្យសុំលេខសម្គាល់ម្ចាស់អាជីវកម្ម៖
  - irs.gov
- ☐ ចុះបញ្ជីរចនាសម្ព័ន្ធអាជីវកម្មរបស់អ្នក ជាមួយលេខាធិការរដ្ឋ កាលីហ្វ័រញ៉ា៖
  - sos.ca.gov/business-programs

ជំហានទី ៥៖ មានអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត

- ☐ ដាក់ពាក្យសុំលិខិតអនុញ្ញាតលក់ដូររបស់រដ្ឋកាលីហ្វ័រញ៉ា៖
  - នាយកដ្ឋានពន្ធដារ និងការគ្រប់គ្រងសោហ៊ុយរបស់រដ្ឋ កាលីហ្វ័រញ៉ា
  - cdtfa.ca.gov
- ☐ យកអាជ្ញាប័ណ្ណអាជីវកម្មពីសាលាក្រុងឡុងប៊ិច
  - 562.570.6211 និង LBBiz@longbeach.gov
- ☐ ឆែកមើលលិខិតអនុញ្ញាតជាក់លាក់ (ឧទាហរណ៍ សុខាភិបាល គ្រឿងគ្រោះថ្នាក់ និងការលក់គ្រឿងស្រវឹង)
  - longbeach.gov/permitcenter
- ☐ ទាក់ទងនាយកដ្ឋានផ្សេងរបស់ក្រុង ដើម្បីសុំការណែនាំ។
- ☐ ណាត់ឲ្យគេចុះធ្វើអធិការកិច្ច ដែលកំណត់ដោយច្បាប់។

ជំហានទី ៦៖ កសាងក្រុមរបស់អ្នក

- ☐ រៀបចំផែនការរើសបុគ្គលិក និងព្រាងលក្ខខណ្ឌការងារ។
- ☐ ឲ្យបុគ្គលិកបំពេញពាក្យសម្រាប់បង់ពន្ធ៖
  - ទម្រង់ Form I-9: uscis.gov/i-9
  - ទម្រង់ W-4: irs.gov/w4
- ☐ មានធានារ៉ាប់រងសម្រាប់ប្រាក់ឈ្នួលបុគ្គលិក៖
  - នាយកដ្ឋានទំនាក់ទំនងឧស្សាហកម្មរដ្ឋកាលីហ្វ័រញ៉ា៖ dir.ca.gov
- ☐ រកមើលឱកាសបណ្តុះបណ្តាលអាជីវកម្ម ជាមួយបណ្តាញវានុវត្តន៍កម្លាំងពលកម្មក្រុងឡុងប៊ិច៖
  - longbeach.gov/workforce

រកទីផ្សារ បើកហាង និងជោគជ័យ

ជំហានទី ៧៖ រកទីផ្សារអាជីវកម្មរបស់អ្នក

- □ បង្កើតផែនការទីផ្សាររបស់អ្នក ដោយមានគោលដៅ និងសារ។
  - ការកែលម្អអាជីវកម្មក្នុងសង្កាត់៖ longbeach.gov/bids
  - ទស្សនាទីក្រុងឡុងប៊ិច៖ visitlongbeach.com
- □ ផ្សព្វផ្សាយតាមអនឡាញឲ្យគេស្គាល់៖
  - វិធានគេហទំព័រ៖ Squarespace, Wix និង WordPress.
  - គណនីប្រព័ន្ធផ្សព្វផ្សាយសង្គម៖ Facebook, X, Instagram និង LinkedIn.
- □ ចុះឈ្មោះអាជីវកម្មរបស់អ្នកតាម Yelp និង Trip Advisor។
- □ រចនាឯកសារផ្សព្វផ្សាយពាណិជ្ជកម្ម ដោយបោះពុម្ពនៅរោងពុម្ពមូលដ្ឋាន។
- □ ចូលរួមកម្មវិធីចងបណ្តាញក្នុងមូលដ្ឋាន៖
  - សភាពាណិជ្ជកម្មតំបន់ក្រុងឡុងប៊ិច៖ 562.436.1251 និង lbchamber.com

ជំហានទី ៨៖ ត្រៀមរៀបចំបើកហាង

- □ បង្ហើយលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងអធិការកិច្ច។
- □ ទិញ ឬជួលសម្ភារៈ និងការរៀបចំស្តុកភស្តុភារ។
- □ ធ្វើតេស្តផលិតផល ឬសេវា ដោយបើកសាកសិន។
- □ ប្រកាសថ្ងៃបើកហាង និងរៀបចំពិធីកាត់ខ្សែបូ ដោយអញ្ជើញខាងសាលាក្រុងចូលរួម។

ជំហានទី ៩៖ បន្តអនុវត្តច្បាប់

- □ បង់ពន្ធអាជីវកម្ម៖
- □ បន្តសុពលភាពអាជីវកម្មរាល់ឆ្នាំ។
- □ រក្សាទុកឯកសារប្រតិបត្តិការអាជីវកម្មឲ្យបានល្អ ដោយមានកម្មវិធីជួយ។

ជំហានទី ១០៖ ធ្វើឲ្យអាជីវកម្មជោគជ័យ

- □ ត្រួតពិនិត្យហិរញ្ញវត្ថុ និងសម្រួចយុទ្ធសាស្ត្រ។
- □ រកមើលជំនួយថវិកា ដើម្បីពង្រីកអាជីវកម្ម។
- □ កសាងដៃគូរជាមួយអង្គការក្នុងមូលដ្ឋាន និងបន្តប្រើប្រាស់ធនធានអាជីវកម្ម ដែលគេផ្តល់ជូន។
- □ រកមើលឱកាសម៉ៅការជាមួយសាលាក្រុង និងតំបន់។
  - Long Beach Buys: longbeachbuys.com
  - Los Angeles County: lacounty.gov/business

យើងខ្ញុំត្រៀមខ្លួនជានិច្ចដើម្បីជួយ ឲ្យអាជីវកម្មរបស់អ្នករីកចម្រើន និងជោគជ័យ!

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច និងឱកាសក្រុងឡុងប៊ិច
កម្មវិធីជួយអាជីវកម្ម BizCare
562.570.4BIZ (4249)
BizCare@longbeach.gov

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច និងឱកាសក្រុងឡុងប៊ិច
បណ្តាញវានុវត្តន៍កម្លាំងពលកម្មក្រុងឡុងប៊ិច
Long Beach Workforce Innovation Network
562.570.3700

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ក្រុងឡុងប៊ិច
មណ្ឌលផ្តល់លិខិតអនុញ្ញាត
562.570.5223

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ
ផ្នែកអាជ្ញាបណ្ណអាជីវកម្ម
562.570.6211

នាយកដ្ឋានពន្លត់អគ្គិភ័យក្រុងឡុងប៊ិច
562.570.2500

នាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋក្រុងឡុងប៊ិច
562.570.4000

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច និងឱកាសក្រុងឡុងប៊ិច
411 W. Ocean Blvd., 10th Floor
Long Beach, CA 90802

សូមចូលមើលគេហទំព័ររបស់យើង៖ longbeach.gov/edo

@LBEconDev

ដើម្បីស្នើសុំព័ត៌មាននេះ ជាទម្រង់ផ្សេងពីនេះ ឬស្នើសុំការសម្របសម្រួលសម្រាប់ជនពិការតាមការគួរណាមួយ សូមទាក់ទងនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច និងឱកាស EDOMedia@longbeach.gov។ យើងខ្ញុំត្រូវការពេលយ៉ាងតិចបី(៣)ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីដោះស្រាយជូនតាមសំណូមពរ។ ទោះជាយ៉ាងនេះក្តី យើងខ្ញុំនឹងខិតខំ ធ្វើយ៉ាងណាដើម្បីឆ្លើយតបទៅតាមសំណូមពរ ទោះសំណើដាក់ឃើតពេលជាងរយៈពេលកំណត់នេះ។